# ថ្ងៃដ៏ស្រងូតស្រងាត់ ខណៈពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីឡើងធ្វើសក្ខីកម្ម

*ដោយ ម៉ៃយឺល សាឡឺបា*

*ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត កែសម្រួលដោយ វ៉ាន់ថាន់ ពៅដារ៉ា*

ថ្ងៃនេះគឺជាថ្ងៃដ៏ស្រងូតស្រងាត់បំផុតចាប់តាំងពីមានសវនាការលើជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានដំណើរការ ខណៈពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានផ្ដល់ឱកាសឲ្យចែករំលែករឿងរ៉ាវឈឺចាប់របស់ខ្លួននៅក្នុងអង្គសវនាការទាំងមូល ។

## ម្ដាយ និងកូនស្រី ស្ដ្រីមេម៉ាយ និងកូនកំព្រា

ជាកិច្ចដំបូងនៃដំណើរការនីតិវិធីនៅក្នុងថ្ងៃនេះ ចៅក្រមបានកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាទីន លើហ្វឺវ (Martine Lefeuvre) ដើម្បីអានសេចក្ដីថ្លែងការណ៍របស់អ្នកស្រី ។ សម្រាប់ការណែនាំខ្លួន ហើយយោងតាមការស្នើសុំរបស់ចៅក្រម មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា លើហ្វឺវ បានរៀបការជាមួយនឹង អ៊ុក កេត ជាអ្នកទោសម្នាក់ដែលត្រូវបានសម្លាប់នៅគុកទួលស្លែង (មន្ទីរស-២១) ។ លើហ្វឺវ និង អ៊ុក កេត បានជួបគ្នានៅទីក្រុងប៉ារីស ហើយបានរៀបការនៅខែតុលា ឆ្នាំ១៩៧១ ។ ក្រោយពីអ្នកទាំងពីរបានរៀបការមក ក្រុមគ្រួសាររបស់អ្នកទាំងពីរបានផ្លាស់ទៅរស់នៅប្រទេសសេណេហ្កាល់ ជាប្រទេសដែល អ៊ុក កេត បំរើជាអ្នកការទូតតំណាងឲ្យប្រទេសកម្ពុជា ។ ក្នុងអំឡុងពេលរស់នៅទីនោះ លើហ្វឺវ បានផ្ដល់កំណើតឲ្យកូនពីរនាក់ គឺកូនប្រុសមួយ និងកូនស្រីមួយ ។

នៅខែមេសា ឆ្នាំ១៩៧៧ អ៊ុក កេត បានទទួលលិខិតឆ្លើយតបមួយច្បាប់ពីក្រសួងការបរទេស ដែលស្នើសុំឲ្យលោកត្រឡប់មកទីក្រុងភ្នំពេញវិញ ។ យោងតាមសម្ដីរបស់ លើហ្វឺវ, អ៊ុក កេត តែងតែរំពឹងចាំឱកាសវិលត្រឡប់មកកាន់ប្រទេសកំណើតរបស់គាត់ណាស់ ពីព្រោះគាត់ចង់ចូលរួមកសាងប្រទេសជាតិ ។ អ៊ុក កេត មានភាពជឿជាក់ថា ប្រទេសជាតិមានស្ថានភាពល្អប្រសើរ ហើយគាត់មិនខ្វាចនឹងវិលត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញឡើយ ។ យ៉ាងណាមិញ មុនពេលដែល អ៊ុក កេត ចាកចេញទៅ លើហ្វឺវ បានប្រាប់ប្ដីរបស់គាត់ថា ប្រសិនបើអ្នកស្រីទទួលដំណឹងថា ប្ដីស្លាប់នោះ គាត់នឹងមិន

ជឿថា ប្តីស្លាប់ដោយសាររោគគាំពាធនោះទេ ។ នៅពេលដែលឮដូច្នេះ អ៊ុក កេត បានឆ្លើយតបថា “ប្រពន្ធសំឡាញ់ ប្រជាជនកម្ពុជាមិនមែនជាមនុស្សសាហាវឃោរឃៅនោះទេ” ។

ក្រុមគ្រួសាររបស់អ្នកស្រីបានទទួលកាតប៉ុស្តាល់ចំនួនពីរពី អ៊ុក កេត បន្ទាប់ពីលោកបានចាកចេញទៅប្រទេសកម្ពុជា ។ ប៉ុន្តែក្រោយពីទទួលបានលិខិតឆ្លើយតបលើកទីពីរនេះមកក្រុមគ្រួសាររបស់អ្នកស្រីមិនដែលឮដំណឹងអ្វីពីប្តីរបស់គាត់ឡើយ ។ ដោយមិនទទួលបានដំណឹងអ្វីសោះអស់រយៈពេលបីខែ លើហ៊ឺវ បានទាក់ទងស្ថានទូតចិន (កាតប៉ុស្តាល់ចុងក្រោយបង្អស់ដែល អ៊ុក កេត បានផ្ញើ គឺនៅពេលដែលលោកទៅដល់ប្រទេសចិន) អង្គការកាកបាទក្រហម និងអង្គការលើកលែងទោសអន្តរជាតិ ដើម្បីស្វែងរកជំនួយនិងព័ត៌មានរបស់ អ៊ុក កេត ។ អ្នកស្រីក៏បានទាក់ទងសម្តេចព្រះ នរោត្តម សីហនុ ដែលអ្នកស្រីធ្លាប់បានចូលគាល់ព្រះអង្គមួយដងដែរ ។ ទោះបីជាខិតខំព្យាយាមប៉ុណ្ណាក៏ដោយ ក៏អ្នកស្រីមិនអាចទទួលបានព័ត៌មានអ្វីបន្ថែមទាក់ទិននឹងប្តីរបស់គាត់ឡើយ ។

នៅដើមឆ្នាំ១៩៨០ លើហ៊ឺវ បានធ្វើដំណើរមកកាន់ជំរំជនភៀសខ្លួននៅប្រទេសថៃ ដើម្បីស្វែងរកដំណឹងរបស់ប្តីគាត់ ។ នៅទីនោះ អ្នកស្រីបានជួបជាមួយមិត្តចាស់ម្នាក់ដែលបានប្រាប់គាត់ថា គាត់បានឃើញឯកសារទាក់ទងនឹងប្តីរបស់គាត់នៅមន្ទីរស-២១ ។ មិត្តរបស់អ្នកស្រីបានប្រាប់ពីព័ត៌មានដ៏អាក្រក់ថា ប្តីរបស់គាត់ត្រូវបានចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីរស-២១ និងសម្លាប់នៅទីនោះតែម្តង ។

ក្រោយពីដឹងពីដំណឹងអាក្រក់នេះហើយ អ្នកស្រីបានវិលត្រឡប់មកកាន់ទីក្រុងប៉ារីសវិញដោយខូចចិត្តយ៉ាងខ្លាំង ។ អ្នកស្រីបានព្យាយាមរៀបចំជីវិតសារជាថ្មីជាមួយនឹងកូនៗរបស់អ្នកស្រីទាំងដឹងថា កូនៗរបស់គាត់នឹងត្រូវធំដឹងក្តីដោយកំព្រាឪពុក ។ ដំបូង អ្នកស្រីមិនអាចប្រាប់ការពិតពីជោគវាសនារបស់ អ៊ុក កេត ទៅកាន់កូនៗរបស់អ្នកស្រីបានឡើយ ។ ទោះបីជាព្យាយាមទាំងកម្លាំងកាយចិត្តយ៉ាងណាក៏ដោយ វាពិតជាលំបាកណាស់សម្រាប់ លើហ៊ឺវ ក្នុងការបន្តជីវិតគ្រួសារដោយគ្មាន អ៊ុក កេត ។

នៅឆ្នាំ១៩៩០ លើហ៊ឺវ បានទទួលសំបុត្រពីម្តាយក្មេករបស់អ្នកស្រីឲ្យអ្នកស្រីវិលមកកាន់ប្រទេសកម្ពុជាវិញរួមជាមួយនឹងកូនទាំងពីរ ។ ពេលមកដល់ប្រទេសកម្ពុជាហើយ អ្នកស្រីនិងកូនៗ បានទៅទស្សនាមន្ទីរស-២១ជាលើកដំបូង ។ អ្នកស្រីភ័យរន្ធត់ចំពោះអំពើសាហាវឃោរឃៅដែលកើតមានឡើងនៅទីនោះ ។ អ្នកស្រីមានអារម្មណ៍ក្រៀមក្រំនិងខឹងសម្បាយ៉ាងខ្លាំង ។ បន្ទាប់មកទៀត លើហ៊ឺវ ក៏បានទៅ

ទស្សនាវាលពិឃាតបឹងជើងឯកដែលអ្នកស្រីបានរៀបរាប់ថា     គាត់មានអារម្មណ៍ខ្ទើមរអើមយ៉ាងខ្លាំង នៅពេលដែលបានឃើញលលាដ៍ក្បាលជាច្រើនដាក់គរលើគ្នា ។ មួយសប្តាហ៍ក្រោយមក អ្នកស្រីក៏បាន ទៅកាន់មន្ទីរស-២១ម្តងទៀត ដើម្បីពិភាក្សាពីកំណត់ត្រានិងឯកសារ ហើយបានរកឃើញថា ប្តីរបស់ អ្នកស្រីត្រូវបានបញ្ជូនមកកាន់មន្ទីរស-២១ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ និងត្រូវបានសម្លាប់ នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧ ។

លើហ៊ឺវ តែងតែចាត់ទុកប្តីរបស់អ្នកស្រីថា ជាមនុស្សស្លូតត្រង់ និងចិត្តល្អ ។ អ៊ុក កេត គឺជាបញ្ញវន្ត មួយរូប ។ លើសពីនេះ លោកគឺជាស្វាមីដ៏គួរឲ្យស្រឡាញ់ និងជាឪពុកដែលពោរពេញដោយក្តីស្រឡាញ់ ចំពោះកូន ។ លើហ៊ឺវ បានរៀបរាប់ថា "ជីវិតរស់នៅជាមួយនឹង អ៊ុក កេត គឺមានសុភមង្គលជាទី បំផុតសម្រាប់ខ្ញុំ" ។ អ្នកស្រីបន្តទៀតថា គ្មានមួយថ្ងៃណាដែលអ្នកស្រីមិនគិតពីប្តីរបស់អ្នកស្រីឡើយ ។ ភាពឈឺចាប់របស់ប្តីអ្នកស្រី គឺនៅតែជាភាពឈឺចាប់របស់អ្នកស្រីរហូត ហើយភាពឈឺចាប់នេះនឹងកាន់ តែកើនឡើងទៅតាមពេលវេលា ។

អ្នកស្រីបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដាក់ទោស"កម្រិតធ្ងន់បំផុត" លើជនជាប់ចោទ ពីព្រោះថា ទណ្ឌកម្មត្រូវតែមានលក្ខណៈស្មើនឹងទម្ងន់នៃឧក្រិដ្ឋកម្ម ។ អ្នកស្រីបាននិយាយទាំងភាពស្រងូតស្រងាត់ថា គាត់មិនអាចអត់ឱនទោសឲ្យជនជាប់ចោទបានឡើយ ។ ជាការឆ្លើយតប ឌុច សូមទទួលស្គាល់ការពិត នៃសក្ខីកម្មរបស់ លើហ៊ឺវ និងសូមការអត់ឱនទោសពីអ្នកស្រីផង ។

កូនស្រីរបស់ អ៊ុក កេត ដែលមានឈ្មោះថា អ៊ុក នារី បានឡើងធ្វើសក្ខីកម្មបន្ទាប់ពីម្តាយរបស់នាង ។ នារី មានអាយុត្រឹមតែពីរឆ្នាំប៉ុណ្ណោះនៅពេលដែលនាងបានជួបមុខឪពុករបស់នាងជាលើកចុងក្រោយ ។ សក្ខីកម្មរបស់ នារី បានបង្ហាញថា សូម្បីតែកូនដែលមិនស្គាល់ឪពុកនៅតែទទួលរងនូវភាពឈឺចាប់ និង ទុក្ខលំបាកវេទនាដោយសារតែគ្មានឪពុក ។

នារី បានរៀបរាប់ថា ការធំដឹងក្តីដោយគ្មានឪពុកតាំងពីវ័យក្មេងហាក់បីដូចជាមានអារម្មណ៍ថា ធម្មតា ។ ប៉ុន្តែការគិតដូច្នេះបានផ្លាស់ប្តូរទាំងស្រុងនៅពេលដែលនាងមានអាយុ១៦ឆ្នាំ     ខណៈពេលដែលនាងបាន មកដល់មន្ទីរស-២១ជាមួយនឹងម្តាយរបស់នាង ។ នារី បានចាត់ទុកបទពិសោធន៍ទាំងនោះជារឿងរន្ធត់ បំផុតក្នុងជីវិតរបស់នាង     ហើយចាត់ទុកការទស្សនានៅវាលពិឃាតបឹងជើងឯកជា"ទីកន្លែងដ៏សាហាវ

ឃោរឃៅបំផុតនៅក្នុងពិភពលោក» ។ នារី បានរៀបរាប់ពីការពិតមួយដែលថា នាងអាចមានជោគវាសនាដូចកូនក្មេងទាំងនោះដែរដែលត្រូវចាប់ជើងលើកឡើងលើ រួចបោកក្បាលនឹងគល់ឈើ ។ នារី បានចាត់ទុកទង្វើរបែបនេះជា«ដំណើរទៅកាន់នរក» ។ ទិដ្ឋភាពនៅមន្ទីរស-២១ នៅតែតាមលងបន្លាចនារី រហូត ទោះបីជានាងរស់នៅប្រទេសបារាំងក៏ដោយ ។ នារី បានបញ្ជាក់ថា ភាពឈឺចាប់នៅមន្ទីរស-២១មិនមែនមានតែនៅក្នុងបន្ទប់ឃុំឃាំងតែប៉ុណ្ណោះទេ ប៉ុន្តែភាពឈឺចាប់នេះបានរាលដាលនៅទូទាំងប្រទេសកម្ពុជា ។

នៅទីបញ្ចប់ នាងបានថ្លែងដោយសង្កត់ធ្ងន់ថា រឿងរ៉ាវរបស់នាង គឺជាហេតុផលមួយដើម្បីដាក់ទោសកម្រិតធ្ងន់លើជនជាប់ចោទ ។ ដូចគ្នានឹងរឿងរ៉ាវរបស់ជនរងគ្រោះចំនួន ១៧.០០០នាក់ផ្សេង ទៀត ក៏ជាហេតុផលចំនួន១៧.០០០ករណី ដើម្បីដាក់ទោសកម្រិតធ្ងន់ ។

## គ្រួសារមួយត្រូវបានបំផ្លាញ

ដើមបណ្តឹងរដ្ឋប្បវេណីទីពីរដែលនឹងចូលមកធ្វើសក្ខីកម្មនៅក្នុងថ្ងៃនេះដែរគឺ រ៉ូប៊ីត ហាមីល ជាកីឡាករអុំទូកប្រណាំងជនជាតិណូវែលហ្សឺឡង់ម្នាក់ដែលបងប្រុសរបស់គាត់ឈ្មោះ ឃេរី ហាមីល ត្រូវបានចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីរស-២១ និងត្រូវបានសម្លាប់ក្នុងអំឡុងរបបគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ ។ រ៉ូប៊ីត បានរៀបរាប់ពីដំណើរជីវិតដ៏ឈឺចាប់ និងកំសត់ដែលរូបលោកនិងគ្រួសារបានរងទុក្ខ និងនៅតែរងទុក្ខដោយសារតែការបាត់ខ្លួនដោយការសម្លាប់បងប្រុសជាទីស្រឡាញ់ ។ ដំណើរជីវិតនេះ មិនមែនជារឿងសោកនាដកម្មមួយដែលរងទុក្ខដោយបុរសម្នាក់ទេ ប៉ុន្តែគឺសមាជិកគ្រួសារទាំងមូលតែម្តង ។ ដូចដែលសាក្សីបានពន្យល់ប្រាប់ «ការបែកបាក់ក្រុមគ្រួសាររបស់ខ្ញុំ គឺជាការបែកបាក់នៅក្នុងជីវិតរបស់ខ្ញុំ» ។

រ៉ូប៊ីត ហាមីល បានធំដឹងក្តីជាមួយនឹងបងប្អូនបួននាក់នៅក្នុងគ្រួសារដែលពោរពេញដោយក្តីស្រឡាញ់មួយនៅប្រទេស ណូវែលហ្សឺឡង់ ។ រ៉ូប៊ីត គឺជាកូនពៅ ហើយ ឃេរី គឺជាកូនច្បង ។ នៅអាយុ២៦ឆ្នាំ ឃេរី បានធ្វើដំណើរតាមកប៉ាល់មួយឆ្លងកាត់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ជាមួយនឹងមិត្តស្រីរបស់គាត់ និងមិត្តភក្តិជាច្រើននាក់ទៀត ។ ឃេរី តែងតែផ្តល់ដំណឹងមកក្រុមគ្រួសាររបស់គាត់ ដែលរំពឹង

រង់ចាំសំបុត្រគាត់ ។ ជាក់ស្តែងក្នុងអំឡុងពេលនោះ យេរី គឺស្ថិតនៅក្នុងវ័យដែលចូលចិត្តកំសាន្តនឹង សកម្មភាពផ្សេងៗ ហើយកំពុងតែរីករាយជាមួយនឹងជីវិតរស់នៅរបស់គាត់ ។

ប៉ុន្តែអ្វីៗទាំងប៉ុន្មានបានបញ្ចប់ទៅទាំងក្តីសោកសង្រេងកាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៨ ។ ប៉ុន្មាន សប្តាហ៍មុនពេលទៅដល់ប្រទេសកម្ពុជា យេរី បានសរសេរសំបុត្រមួយច្បាប់ផ្ញើមកកាន់ក្រុមគ្រួសារ របស់គាត់នៅពេលដែលគាត់ទៅដល់ប្រទេសសង្ហបុរី ។ នេះគឺជាសំបុត្រមួយច្បាប់ចុងក្រោយដែលក្រុម គ្រួសាររបស់គាត់ទទួលបាន ។ ការបាត់ដំណឹងជាបន្តបន្ទាប់បានធ្វើឲ្យក្រុមគ្រួសាររបស់ យេរី មានភាព អន្ទះអន្ទែងយ៉ាងខ្លាំង ។ ម្តាយរបស់ យេរី តែងតែសម្លឹងមើលទៅទឹកសមុទ្រក្នុងរយៈពេលយ៉ាងយូរ ហើយតែងតែនិយាយថា «មិនមានរឿងអ្វីកើតឡើងទេ! យេរី នឹងវិលត្រឡប់មកវិញស្ងាត់ៗ ដើម្បី ធ្វើឲ្យយើងទាំងអស់គ្នាភ្ញាក់ផ្អើល» ។ ពេលវេលាបានកន្លងផុតទៅបាត់សូន្យឈឹង ខណៈពេលដែលក្រុម គ្រួសាររបស់ យេរី រង់ចាំដំណឹងថាគាត់នៅឯណា ។ ទោះបីជា រ៉ូបឹត ហាមីល រួមជាមួយនឹងក្រុម គ្រួសាររបស់គាត់នៅតែមានសង្ឃឹមថា យេរី នឹងវិលត្រឡប់មកវិញក៏ដោយ ពួកគេបានដឹងថា រឿង អាក្រក់ពិតជាបានកើតឡើងចំពោះ យេរី ជាមិនខាន ។ ភាពភ័យខ្លាចនេះ បានក្លាយជាការពិតអស់ រយៈពេលមួយឆ្នាំ និងបួនខែ បន្ទាប់ពីពួកគេបានទទួលសំបុត្រជាលើកចុងក្រោយមួយច្បាប់ តាមរយៈ ការអានរបាយការណ៍ដែលមានចុះនៅក្នុងកាសែតមួយថា យេរី ត្រូវបានចាប់ខ្លួនធ្វើទារុណកម្ម និង សម្លាប់នៅមន្ទីរស-២១ ។ ក្រោយមកទៀត ក្រុមគ្រួសាររបស់ យេរី បានដឹងថា ក៏ប៉ាល់របស់ យេរី ត្រូវបានខ្មែរក្រហមវាយប្រហារ ហើយ យេរី ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ។

ក្រោយពីបានដឹងដំណឹងអាក្រក់នេះហើយ ក្រុមគ្រួសាររបស់ យេរី អស់សង្ឃឹមយ៉ាងខ្លាំង ហើយចាប់ ផ្តើមបែកបាក់គ្នា ។ ចន ដែលជាបងប្រុសរបស់ រ៉ូបឹត ដែរនោះមានអាយុតិចជាង យេរី មួយឆ្នាំ ។ យេរី និង ចន មានភាពស្និទ្ធស្នាលជាមួយគ្នាយ៉ាងខ្លាំង ។ ក្នុងអំឡុងពេល១៦ខែចន្លោះពេលដែល យេរី បានបាត់ខ្លួន និងពេលដែល ចន បានដឹងពីដំណឹងអាក្រក់នោះមក ចន ខូចចិត្តយ៉ាងខ្លាំង និង បានបញ្ចប់ជីវិតរបស់គាត់ដោយលោតសម្លាប់ខ្លួនពីលើជ្រោះ ។ ចន បានស្លាប់នៅអាយុ២៧ឆ្នាំ ដូចគ្នា នឹងអាយុរបស់ យេរី នៅពេល យេរី ស្លាប់ដែរ ។ រ៉ូបឹត ដឹងថា គ្មានអ្វីដែលអាចបំបែកអ្នកទាំងពីរ បានឡើយ ។ គាត់បានបញ្ជាក់ថា ប្រសិនបើ យេរី នៅមានជីវិតនោះ ចន ក៏នៅមានជីវិតរស់នៅ រហូតមកដល់សព្វថ្ងៃនេះដែរ ។ រ៉ូបឹត បានងាកមកកាន់ជនជាប់ចោទហើយនិយាយទាំងទុក្ខសោកថា «ឌុច នៅពេលដែលអ្នកសម្លាប់បងប្រុសខ្ញុំ យេរី អ្នកក៏បានសម្លាប់បងប្រុសខ្ញុំ ចន ដែរ» ។

បន្ទាប់មកទៀត រ៉ូបឺត បានរៀបរាប់ពីភាពឈឺចាប់របស់ម្ដាយគាត់ ។ បើទោះបីជាម្ដាយរបស់គាត់រឹងប៉ឹងនៅចំពោះកូនៗទាំងអស់ក៏ដោយ ភាពឈឺចាប់ដែលមាននៅក្នុងចិត្តរបស់គាត់បានធ្វើឲ្យគាត់ធ្លាក់ខ្លួនឈឺ ។ ម្ដាយរបស់ រ៉ូបឺត បានឈប់ចូលរួមសកម្មភាពក្នុងសង្គម ។ គួរឲ្យសោកស្ដាយគាត់បានចែកឋាននៅឆ្នាំ២០០៣ មុនពេលដែលគាត់បានឃើញយុត្តិធម៌ដែលនឹងសម្រេចបានសម្រាប់ការស្លាប់របស់កូនប្រុសគាត់ទាំងពីរនាក់ ។ ឪពុករបស់ រ៉ូបឺត ជួបប្រទះនឹងផលលំបាកជាច្រើននៅពេលដែលបាត់បង់កូនប្រុសទាំងពីរនាក់ ។ ជាលទ្ធផល ឪពុកម្ដាយរបស់ រ៉ូបឺត មិនមានសមត្ថភាពធ្វើជាឪពុកម្ដាយតទៅទៀតបានទេ ។ ធ្លាក់ខ្លួនពិការដោយជម្ងឺស្លាប់មួយដងខ្លួន មិនអាចក្លាយជាមនុស្សធម្មតាបានឡើយ ។

ជាចុងក្រោយ រ៉ូបឺត បានរៀបរាប់ពីការតស៊ូ និងភាពឈឺចាប់របស់លោក ។ ទិដ្ឋភាពនៃព្រឹត្តិការណ៍ជុំវិញការស្លាប់របស់បងប្រុសលោកបានលងបន្លាចគាត់តាំងពីគាត់មានអាយុ១៦ឆ្នាំ ហើយនៅតែតាមលងបន្លាចគាត់រហូតដល់សព្វថ្ងៃនេះ ។ ដោយសារតែមានភាពតានតឹង និងពោរពេញដោយទុក្ខសោក រ៉ូបឺត ត្រូវបានអនុញ្ញាតឲ្យចាកចេញពីអង្គសវនាការដើម្បីសួរសំណួរទៅកាន់ជនជាប់ចោទដោយផ្ទាល់ ។ ទោះបីជាលោកមានភាពឈឺចាប់ និងខឹងសម្បាដែលគាត់បានលាក់ទុកជាយូរមកហើយក៏ដោយ លោកនៅតែចោទសួរសំណួរដែលមានលក្ខណៈសមរម្យទៅកាន់ជនជាប់ចោទ ។ រ៉ូបឺត បានបង្ហាញឲ្យឃើញនូវកម្លាំងចិត្តដ៏ខ្លាំងក្លាដែលលោកមាន ។ លើសពីនេះទៅទៀត លោកមិនបាននិយាយទៅកាន់ជនជាប់ចោទដោយសម្ដីគំរោះគំរើយ និងភាពខឹងសម្បាឡើយ ។ ប៉ុន្តែ រ៉ូបឺត បានសួរជនជាប់ចោទ ដើម្បីរកចម្លើយដែលអាចជួយលោកនិងក្រុមគ្រួសារឲ្យមានភាពធូរស្បើយពីសោកនាដកម្ម ដែលបានកើតមានឡើងចំពោះក្រុមគ្រួសាររបស់លោកទាំងមូល ។

ក្រោយពីបានស្ដាប់រឿងរ៉ាវដ៏ឈឺចាប់របស់សាក្សីដែលបានបាត់បង់សមាជិកគ្រួសារមក អ្នកគ្រប់គ្នាពិតជាមានអារម្មណ៍អាណិតអាសូរយ៉ាងខ្លាំងចំពោះអ្នកទាំងនោះ ហើយសង្ឃឹមថា អង្គជំនុំជម្រះនេះនឹងផ្ដល់យ៉ាងហោចណាស់ស្មារតីនៃភាពយុត្តិធម៌ដែលអាចនឹងសម្រេចបាននាពេលខាងមុខ ។